FORUM-ASIA

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សមាគមអាដហុក
ADHOC

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

icj International Commission of Jurists

CIVIL RIGHTS DEFENDERS

ISHR | INTERNATIONAL SERVICE FOR HUMAN RIGHTS

CIVICUS

fidh

OMCT SOS-Torture Network

HUMAN RIGHTS WATCH

Human Rights Now

គោរពជូនតំណាងអចិន្ត្រៃយ៍នៃសមាជិក និងអ្នកឃ្លាំមើលរដ្ឋភាគីនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

ទីក្រុងហ្សឺណែវ, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦

# សូមអំពាវនាវឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្សអនុម័តដំណោះស្រាយមួយនៅលើបញ្ហាស្ថានភាពសិទ្ធិមនុស្សដែលកំពុងមានភាពតានតឹងនៅក្នុងប្រទេសកម្ពុជា

យើងខ្ញុំ ជាអង្គការសង្គមស៊ីវិលកម្ពុជា និងសង្គមស៊ីវិលអន្តរជាតិ មានរាយនាមដូចខាងក្រោម សូមស្នើគណៈប្រតិភូនៃក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីចូលរួមគាំទ្រអនុម័តដំណោះស្រាយមួយ ស្តីពីស្ថានភាពសិទ្ធិមនុស្សដែលកំពុងមានភាពតានតឹងនៅក្នុងប្រទេសកម្ពុជា ខណៈដែលសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សលើកទី៣៣នឹងត្រូវប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦។

ដំណោះស្រាយនេះ គួរតែថ្កោលទោសទៅលើការរំលោភសិទ្ធិមនុស្សជាលក្ខណៈប្រព័ន្ធ និងបញ្ឈប់និទណ្ឌភាពចំពោះជនប្រព្រឹត្តបទល្មើសដែលកំពុងកើតមានជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជា។ ការអនុម័តនេះ គួរតែរិះរកដំណោះស្រាយលើកង្វល់នានាដែលបានលើកឡើងដោយ

ប្រទេសជាច្រើនកាលពីសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សលើកទី៣២ និងជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជាកែតម្រូវសកម្មភាពជាបន្ទាន់ដើម្បីរក្សារសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសដែលបានបង្កើតឡើងរយៈពេល២៥ឆ្នាំមកហើយ និងដើម្បីធានាការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតជាតិឆ្នាំ២០១៨ នាពេលខាងមុខនេះ។ ដំណោះស្រាយគួរតែស្នើទៅអ្នកស្រី Rhona Smith អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិលើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដើម្បីវាយតម្លៃពីការអនុវត្តអនុសាសន៍ដែលបានដាក់ជូនទៅរាជរដ្ឋាភិបាលកម្ពុជាដោយស្ថាប័ន និងយន្តការអង្គការសហប្រជាជាតិជាច្រើន រួមបញ្ចូលទាំងអនុសាសន៍របស់អ្នកស្រី និងអតីតអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិកន្លងមក។ ការវាយតម្លៃនោះគឺដើម្បីកំណត់គោលការណ៍សម្រាប់ដំណើរការ និងតំបន់អាទិភាព ដើម្បីធ្វើការកែប្រែក្នុងការបញ្ចប់ការរំលោភសិទ្ធិមនុស្សជាលក្ខណៈប្រព័ន្ធដែលបានកើតឡើងជាបន្តបន្ទាប់។

អាណត្តិរបស់អ្នករាយការណ៍ពិសេសនៅកម្ពុជាត្រូវបានបន្តរយៈពេលចំនួនពីរឆ្នាំទៀតក្នុងសម័យប្រជុំលើកទី៣០នៃក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ។ នេះជាការអនុវត្តតែមួយគត់នៃដំណោះស្រាយជាក់លាក់ប្រចាំឆមាសរបស់ប្រទេស ដែលនឹងផ្តល់សារសំខាន់នៃការបន្តឃ្លាំមើល និងការរាយការណ៍ជាសាធារណៈពីស្ថានភាពនៅក្នុងប្រទេស និងជួយបង្កើនប្រសិទ្ធភាពការងារនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ទោះបីជាយ៉ាងណា ការងារនេះនៅតែត្រូវការក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងការប្រើប្រាស់ទំនួលខុសត្រូវរបស់ខ្លួនដើម្បីចាត់វិធានការទៅលើស្ថានភាពដ៏តានតឹងនៅក្នុងប្រទេសកម្ពុជា។

## ការវិវត្តន៍ចុងក្រោយ

ចាប់តាំងពីយើងខ្ញុំ បានបង្ហាញក្តីកង្វល់យ៉ាងជ្រាលជ្រៅនៅក្នុងលិខិតមួយស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដែលបានផ្ញើរទៅគណៈប្រតិភូរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងគណៈប្រតិភូផ្សេងទៀត មុនពេលសម័យប្រជុំលើកទី៣០នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ការភ័យខ្លាចរបស់យើងខ្ញុំគឺថា ប្រទេសកម្ពុជាបានជួបហានិភ័យ "ការធ្លាក់ចូលកាន់តែជ្រៅនៃការរំលោភសិទ្ធិមនុស្ស ដែលក្លាយទៅជាទម្លាប់ រួមបញ្ចូលទាំងហិង្សានយោបាយ" ហើយអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ ក៏បានបង្ហាញការភ័យខ្លាចថាប្រទេសកម្ពុជាកំពុងត្រូវបានស្ថិតនៅក្នុង "ចំណុចគ្រោះថ្នាក់ខ្លាំង"។

តាមពិតទៅ ចាប់តាំងពីការអនុម័តដំណោះស្រាយក្រុមប្រឹក្សាសិទ្ធិមនុស្សកាលពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងតែឈានទៅរកការរឹតត្បឹតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការជួបជុំនិងប្រមូលផ្តុំដោយសន្តិវិធី ការកម្រិតលទ្ធភាពគណបក្សប្រឆាំងក្នុងការចូលរួមយុទ្ធនាការ និងបង្កើតគោលនយោបាយ និងការរារាំងអង្គការសង្គមស៊ីវិលមិនឲ្យប្រតិបត្តិការដោយសេរី និងឯករាជ្យ។ បទបញ្ញត្តិដែលមានការរឹតត្បឹតហួសហេតុទៅលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានត្រូវបានចូលជាធរមាន រាប់បញ្ចូលទាំងច្បាប់ស្តីពីសមាគមនិងអង្គការមិន

មែនរដ្ឋាភិបាល ដែលការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សបានពិពណ៌នាពីចំនុចអវិជ្ជមានថា "ច្បាប់នេះមិនស្របទៅនឹងវិធាននិងច្បាប់សិទ្ធិមនុស្សអន្តរជាតិ" និង "មានការគំរាមកំហែងទៅលើសង្គមស៊ីវិលដែលធ្វើការដោយសេរី និងឯករាជ្យក្នុងប្រទេសកម្ពុជា" ជាមួយនឹងការព្រួយបារម្ភយ៉ាងខ្លាំងថារាជរដ្ឋាភិបាលកម្ពុជាកំពុងតែរៀបចំប្រើប្រាស់ច្បាប់នេះដើម្បីជាហេតុផលក្នុងការលុបបញ្ជីការអង្គការសមាគមណាដែលបំពានទៅលើអត្ថន័យនៃពាក្យថា "អព្យាក្រឹត្យភាពនយោបាយ"។ ច្បាប់ស្តីពីសហជីពក៏ត្រូវបានអនុម័ត ដែលបង្កើតឲ្យមានការរឹតត្បឹតផ្សេងទៀតទៅលើសិទ្ធិក្នុងជួបជុំដោយសេរី ដែលធ្វើឲ្យសិទ្ធិការងារត្រូវបានធ្លាក់ចុះបន្តទៅទៀតនៅក្នុងប្រទេសកម្ពុជា។ កងកម្លាំងសន្តិសុខនៅតែបន្តបង្ក្រាបទៅលើការតវ៉ាដោយសន្តិវិធី ហើយប៉ុន្មានខែចុងក្រោយនេះ គឺមានការកើនឡើងទ្វេដង នៃការធ្វើទុក្ខបុកម្នេញតាមផ្លូវតុលាការជាបន្តបន្ទាប់ ទៅលើអ្នកការពារសិទ្ធិមនុស្ស សកម្មជនសហគមន៍ សកម្មជនសហជីព សមាជិកនិងអ្នកគាំទ្រគណបក្សជំទាស់។

កាលពីថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៦ អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិចំនួនបួនរូបបានរួមគ្នាអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជា "បញ្ឈប់ការរំលោភបំពានលើសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស តំណាងរាស្ត្រ និងមន្ត្រីអង្គការសហប្រជាជាតិ ហើយសូមចាត់វិធានការឲ្យមានប្រសិទ្ធភាពដើម្បីការពារសង្គមស៊ីវិល និងគោរពសិទ្ធិសេរីភាពជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា"។ អ្នករាយការណ៍ពិសេសទាំងបួនរូបនោះ ក៏បានលើកឡើងពីសំណុំរឿងនៃសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) ដែលជាសមាគមមួយមានវ័យចំណាស់ជាងគេ ធំជាងគេ និងជាអង្គការគោរពសិទ្ធិមនុស្សជាងគេ ខណៈដែលមានមន្ត្រីជាន់ខ្ពស់របស់ខ្លួនចំនួនបួនរូបត្រូវបានចាប់ខ្លួនរួមជាមួយអតីតមន្ត្រីជាន់ខ្ពស់មួយរូប ដែលបច្ចុប្បន្នជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប)។ អ្នកទាំងប្រាំរូបនោះត្រូវបានស៊ើបអង្កេតតាមផ្លូវតុលាការ និងត្រូវឃុំខ្លួនដោយមិនត្រឹមត្រូវទៅលើបទចោទ "សូកប៉ាន់សាក្សី" ដែលប្រជាពលរដ្ឋជាច្រើនយល់ថាជារឿងនយោបាយ ដោយសារអ្នកទាំងនោះគ្រាន់តែផ្តល់ការប្រឹក្សាផ្លូវច្បាប់ និងផ្តល់ជំនួយស្របច្បាប់លើថ្លៃអាហារហូបចុក និងការធ្វើដំណើរ ទៅស្ត្រីម្នាក់ដែលអះអាងថា ធ្លាប់មានទំនាក់ទំនងស្នេហា ជាមួយលោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ។ ការបន្តឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូប ក៏ដូចជាការគំរាមកំហែង និងការបំភិតបំភ័យទៅលើអ្នកដែលហ៊ាននិយាយរិះគន់មិនសំចៃមាត់ រួមបញ្ចូលទាំងការគំរាមកំហែងអ្នកធ្វើយុទ្ធនាការនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមគឺ ជាការគាបសង្កត់កាន់តែខ្លាំងទៅលើសេរីភាពនៃការបញ្ចេញមតិ និងជាសារគំរាមអ្នកដែលហ៊ាននិយាយរិះគន់រាជរដ្ឋាភិបាល។

កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ លោកបណ្ឌិត កែម ឡី អ្នកវិភាគនយោបាយឯករាជ្យដ៏មានប្រជាប្រិយភាព និងជាអ្នកទាមទារយុត្តិធម៌ក្នុងសង្គម ត្រូវបានបាញ់សម្លាប់ទាំងកណ្តាលថ្ងៃចេសនៅក្នុងម៉ាតលក់ទំនិញនៃបរិវេណស្ថានីយប្រេងឥន្ធនៈមួយក្នុងទីក្រុងភ្នំពេញ។ បន្ទាប់ពីការបាញ់ប្រហារនោះ អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិចំនួនប្រាំរូបបានរួមគ្នាលើកឡើង

ថា៖ "ស្ថានភាពឃាតកម្មលើលោកបណ្ឌិត កែម ឡី បានធ្វើឲ្យមានមន្ទិលសង្ស័យជាច្រើនដោយសារលោកជាអ្នករិះគន់រាជរដ្ឋាភិបាល ហើយលោកតែងតែបញ្ចេញទស្សនៈនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមអំពីអភិបាលកិច្ច និងការព្រួយបារម្ភណ៍ពីស្ថានភាពសិទ្ធិមនុស្ស"។ អ្នកទាំងនោះបានលើកឡើងថា ការបាញ់ប្រហារលើលោកបណ្ឌិត កែម ឡី ជា "ឧទាហរណ៍បញ្ជាក់ពីស្ថានភាពអាក្រក់នៅក្នុងប្រទេសកម្ពុជាដែលសកម្មជននយោបាយ និងអ្នកការពារសិទ្ធិមនុស្សកំពុងតែប្រឈមនឹងការរឹតត្បឹតសិទ្ធិសេរីភាព..." ហើយថាឃាតកម្មនេះគឺ "អាចជាការគំរាមកំហែងមួយដែលធ្វើឲ្យប៉ះពាល់ទៅដល់លទ្ធិប្រជាធិបតេយ្យ និងស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា"។ អ្នកទាំងនោះបានបន្តថា៖ "ការស៊ើបអង្កេតដោយឯករាជ្យ និងម៉ត់ចត់ត្រូវតែធ្វើឡើងឲ្យបានឆាប់រហ័សដោយស្ថាប័នឯករាជ្យ ដែលមិនជាប់ទាក់ទងនឹងរាជរដ្ឋាភិបាល" អ្នកទាំងនោះក៏បានអំពាវនាវអោយមានការស៊ើបអង្កេតដែលមិនទាន់បានធ្វើឡើងផងដែរ។

ការវិវត្តន៍ទាំងនេះបានធ្វើឲ្យបរិបទនយោបាយកាន់តែមានភាពតានតឹង ខណៈដែលមេដឹកនាំគណបក្សជំទាស់ លោក សម រង្ស៊ី និងលោក កឹម សុខា ប្រធាន និងអនុប្រធានគណបក្សសង្គ្រោះជាតិ ត្រូវបានដាក់ជាគោលដៅក្នុងការបង្ក្រាប ជាមួយនឹងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌជាច្រើនដែលរារាំងអ្នកទាំងពីរមិនឲ្យចូលរួមជិវិតនយោបាយជាសាធារណៈនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៅទៀត អ្នកទោសនយោបាយចំនួន២៦រូប រាប់បញ្ចូលទាំងអ្នកការពារសិទ្ធិមនុស្សមួយចំនួន គឺកំពុងត្រូវបានឃុំខ្លួនក្នុងប្រទេសកម្ពុជា។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀតបានធ្វើការគំរាមកំហែងអ្នកនយោបាយគណបក្សជំទាស់ អ្នកវិភាគនយោបាយ និងសង្គមស៊ីវិល តាមរយៈបណ្តឹងជាច្រើន រាប់បញ្ចូលទាំង "បទបរិហារកេរ្តិ៍"។ ខណៈពេល មានការធ្វើទុក្ខបុកម្នេញលើសង្គមស៊ីវិល និងសំឡេងអ្នករិះគន់ឯករាជ្យ និងការធ្វើទុក្ខបុកម្នេញលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យកាន់តែខ្លាំងឡើងៗ ភាពតានតឹងផ្នែកនយោបាយទាំងនេះ បានគំរាមកំហែងការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ឆ្នាំ២០១៧ និងឆ្នាំ២០១៨ នាពេលខាងមុខនេះ។

## សារសំខាន់ៗសម្រាប់ស្នើឲ្យមានការឆ្លើយតបពីក្រុមប្រឹក្សាសិទ្ធិមនុស្ស

ស្ថិតក្នុងការប្រឈមនឹងស្ថានភាពសិទ្ធិមនុស្សកាន់តានតឹងយ៉ាងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាគោលនយោបាយរាជរដ្ឋាភិបាល និងការអនុវត្តដែលផ្ទុយទៅនឹងស្មារតីនៃសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស និងផ្ទុយទៅនឹងស្មារតីរបស់អង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសិទ្ធិមនុស្សគួរតែអនុម័តដំណោះស្រាយដូចតទៅ៖

- **ថ្កោលទោស ចំពោះការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញទៅលើ អ្នកការពារសិទ្ធិមនុស្ស និងសំឡេងអ្នករិះគន់ ការរំលោភសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ជួបជុំនិងប្រមូលផ្តុំដោយសន្តិវិធី កង្វះឯករាជ្យភាពនៃប្រព័ន្ធតុលាការ ការរំលោភសិទ្ធិដីធ្លីនិងលំនៅដ្ឋាន ការរំលោភសិទ្ធិស្ត្រីនិងសិទ្ធិជនជាតិដើមភាគតិច ការធ្វើឲ្យបាត់បង់នូវគោលការណ៍និងស្ថាប័នលទ្ធិ**

ប្រជាធិបតេយ្យជាមូលដ្ឋាន និងការបន្តឲ្យកើតមាននិទណ្ឌភាពចំពោះជនប្រព្រឹត្តបទល្មើសនៃការរំលោភសិទ្ធិមនុស្ស។

- សូមជំរុញ ឲ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ឈប់ការរំលោភបំពានដ៏ធ្ងន់ធ្ងរទាំងនេះ ដើម្បីគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សជាតិ និងអន្តរជាតិរបស់ខ្លួន ហើយអនុវត្តកំណែទម្រង់ច្បាប់ និងស្ថាប័នមួយចំនួនដែលអង្គការសហប្រជាជាតិបានលើកឡើងពីសារសំខាន់។
- សូមជំរុញ ឲ្យអាជ្ញាធរកម្ពុជាដោះលែងសកម្មជនទាំងអស់ជាបន្ទាន់ រួមមាន អ្នកការពារសិទ្ធិមនុស្ស អ្នកគាំទ្រនិងសមាជិកគណបក្សជំទាស់ដែលត្រូវបានជាប់ពន្ធនាគារដោយមិនត្រឹមត្រូវ ដោយគ្រាន់តែអ្នកទាំងនោះប្រើប្រាស់សិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់ខ្លួន និងសូមជំរុញឲ្យអាជ្ញាធរកម្ពុជាទម្លាក់ចោលនូវបទចោទទាំងឡាយដែលបានចោទប្រកាន់ទៅលើអ្នកទាំងនោះ។
- សូមអំពាវនាវ ឲ្យអាជ្ញាធរកម្ពុជាធ្វើការស៊ើបអង្កេតជាបន្ទាន់ ដោយឯករាជ្យ មានតម្លាភាព ប្រសិទ្ធភាព មិនលំអៀង និងដោយម៉ត់ចត់ ក្នុងករណីអំពើហិង្សានានា រាប់បញ្ចូលទាំងករណីអង្គរក្សបីនាក់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានវាយប្រហារទៅលើតំណាងរាស្ត្រពីររូបមកពីគណបក្សជំទាស់ កាលពីខែតុលា ឆ្នាំ២០១៥ និងឃាតកម្មលើលោកបណ្ឌិត កែម ឡី អ្នកវិភាគនយោបាយឯករាជ្យ កាលពីថ្ងៃទី១០ ខែកក្កដា ហើយត្រូវយកជនប្រព្រឹត្តបទល្មើសទាំងនោះ រួមទាំងអ្នកផ្តើមគំនិត ឬអ្នកនៅពីក្រោយអំពើហិង្សាទាំងនោះ ដើម្បីយកទៅកាត់ទោសក្នុងសវនាការត្រឹមត្រូវមួយ។
- សូមអំពាវនាវ ឲ្យរាជរដ្ឋាភិបាលកម្ពុជាលុបចោលច្បាប់ទាំងឡាយណាដែលផ្ទុយពីបទដ្ឋានច្បាប់អន្តរជាតិទាក់ទងនឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការជួបជុំនិងប្រមូលផ្តុំដោយសន្តិវិធី ឬធ្វើវិសោធនកម្មលើច្បាប់ទាំងនោះដើម្បីឲ្យស្របជាមួយស្តង់ដាអន្តរជាតិ រួមបញ្ចូលទាំង ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីទូរគមនាគមន៍ ហើយបញ្ឈប់ការអនុម័តបទបញ្ញត្តិទាំងឡាយណាដែលមិនស្របទៅនឹងគោលការណ៍អន្តរជាតិ។
- សូមអំពាវនាវ ឲ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើវិសោធនកម្មច្បាប់បីគឺ "ច្បាប់ស្តីពីកំណែទម្រង់ប្រព័ន្ធតុលាការ" (ច្បាប់ស្តីពីការរៀបចំតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម) ដែលមានការជ្រៀតជ្រែកទៅលើឯករាជ្យភាពនៃប្រព័ន្ធតុលាការ ហើយផ្ទុយពីគោលការណ៍អន្តរជាតិនិងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- សូមអំពាវនាវ ឲ្យរាជរដ្ឋាភិបាលកម្ពុជាបង្កើតផែនការណ៍សកម្មភាពជាក់លាក់សម្រាប់ការអនុវត្តអនុសាសន៍របស់អ្នករាយការណ៍ពិសេសនិងអតីតអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ ក៏ដូចជាយន្តការអង្គការសហប្រជាជាតិ រួមបញ្ចូលទាំងសន្ធិសញ្ញានៃការឃ្លាំមើលសិទ្ធិមនុស្ស ផ្អែកលើនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ការពិនិត្យឡើងវិញជាសកល ការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិ និងអគ្គលេខាធិការនៃ

អង្គការសហប្រជាជាតិ។

- សូមជំរុញ ឲ្យរាជរដ្ឋាភិបាលកម្ពុជាធានាតម្លាភាព និងទំនុកចិត្តនៃដំណើរការបោះឆ្នោត និងបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ការបោះឆ្នោតថ្នាក់ក្រោមជាតិនិងការបោះឆ្នោតថ្នាក់ជាតិនាពេលខាងមុខនេះ ដើម្បីឲ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ ត្រឹមត្រូវ ទំនុកចិត្ត សន្តិភាព និងតម្លាភាព ដោយស្របទៅនឹងការប្តេជ្ញាជាអន្តរជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ សំណើនេះផងដែរក៏សូមជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជា បើកទូលាយការចូលរួមផ្នែកនយោបាយ និងធានាការគោរពសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពជាមូលដ្ឋាន រួមបញ្ចូលទាំងសិទ្ធិក្នុងការបញ្ចេញមតិលើប្រព័ន្ធអ៊ីនធឺណេត សិទ្ធិសេរីភាពក្នុងការជួបជុំនិងប្រមូលផ្តុំដោយសន្តិវិធី។
- សូមអំពាវនាវ ឲ្យរាជរដ្ឋាភិបាលកម្ពុជាបង្កើតស្ថាប័នសិទ្ធិមនុស្ស ដែលមានភាពឯករាជ្យស្របតាមគោលការណ៍នៃស្ថាប័នជាតិសម្រាប់ការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ("គោលការណ៍សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស")។
- សូមអំពាវនាវ ឲ្យរាជរដ្ឋាភិបាលកម្ពុជាសហការឲ្យបានពេញលេញជាមួយអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ ក៏ដូចជាស្ថាប័ន និងយន្តការសិទ្ធិមនុស្សផ្សេងទៀតនៃអង្គការសហប្រជាជាតិ អំពីស្ថានភាព សិទ្ធិមនុស្សនៅកម្ពុជា។
- សូមស្នើ ទៅអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាដើម្បីវាយតម្លៃពីការអនុវត្តអនុសាសន៍ ដែលបានដាក់ជូនទៅរាជរដ្ឋាភិបាលកម្ពុជាដោយស្ថាប័ននិងយន្តការអង្គការសហប្រជាជាតិផ្សេងទៀត រួមបញ្ចូលទាំងអនុសាសន៍របស់អ្នករាយការណ៍ពិសេសបច្ចុប្បន្ននិងអតីតអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ ដើម្បីកំណត់ពីគោលការណ៍រីកចម្រើន និងតំបន់អាទិភាពសម្រាប់ការកែប្រែសមស្របមួយក្នុងការបញ្ចប់ការរំលោភសិទ្ធិមនុស្សជាលក្ខណប្រព័ន្ធ ដែលបានកើតឡើងក្នុងប្រទេសកម្ពុជាកន្លងមក។
- សូមផ្តល់ឱកាសឲ្យ អ្នកទទួលខុសត្រូវលើនីតិវិធីពិសេស ដើម្បីចូលរួមឲ្យបានពេញលេញ និងសម្របសម្រួលជាមួយនឹងអ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា
- សូមរក្សា ភាពសកម្មក្នុងការដោះស្រាយបញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

យើងខ្ញុំ សូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាបង្ហាញការគាំទ្រក្នុងការបន្តអាណត្តិការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិនៅកម្ពុជាដោយការចុះហត្ថលេខាលើអនុស្សរណៈនៃការយល់យោគឲ្យបានឆាប់រហ័សរវាងរាជរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិ និងដើម្បីគូសបញ្ជាក់ពីសារសំខាន់នៃការបន្តអនុស្សរណៈរវាងការងាររបស់អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ ស្ថាប័ននិងយន្តការអង្គការសហប្រជាជាតិដទៃទៀត និងការិយាល័យអង្គការសហប្រជាជាតិប្រចាំប្រទេស។

* * *

ក្រោយពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសរយៈពេល២៥ឆ្នាំ ដំណោះស្រាយនេះគួរតែត្រូវលើកយកមកបញ្ជាក់ជាថ្មីទៀតនៅក្នុងទំនួលខុសត្រូវជាប្រវត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិដើម្បីគាំទ្រប្រជាពលរដ្ឋកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ។ ដោយសារតែសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សលើកទី៣៣នេះជាពេលវេលាចុងក្រោយក្នុងការពិនិត្យលើស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាមុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់មកដល់ (ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧) ក្រុមប្រឹក្សាសិទ្ធិមនុស្សគួរតែមានឆន្ទៈច្បាស់លាស់ក្នុងការបន្តឃ្លាំមើលឲ្យបានជិតដល់ និងដោះស្រាយស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដោយអនុម័តដំណោះស្រាយមួយដែលលើកឡើងពីការព្រួយបារម្ភណ៍ដូចបានរៀបរាប់ខាងលើ និងសូមជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការកែប្រែសកម្មភាពរំលោភបំពានទាំងនេះជាបន្ទាន់។

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ទៅលើបញ្ហាទាំងនេះ និងរីករាយក្នុងការផ្តល់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងបញ្ហាទាំងនេះទៅតាមតម្រូវការ។

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
International Federation for Human Rights (FIDH)
Asian Forum for Human Rights and Development (FORUM-ASIA)
CIVICUS: World Alliance for Citizen Participation
Civil Rights Defenders
International Commission of Jurists
International Service for Human Rights
Human Rights Now
Human Rights Watch
World Organization Against Torture (OMCT)